# សំណួរដែលត្រូវបានសាកសួរញឹកញាប់
# អំពីឆ្នោតផ្សងសំណាងបញ្ជីរង់ចាំ HACSJ

**តើបញ្ជីរង់ចាំណាខ្លះដែលនឹងមាននៅថ្ងៃទី 22 ខែតុលា ឆ្នាំ2018?**

ឆ្នោតផ្សងសំណាងបញ្ជីរង់ចាំសម្រាប់កម្មវិធីបណ្ណសេដ្ឋកិច្ចជម្រើសផ្តល់លំនៅឋាន និងសហគមន៍លំនៅឋានប្រកបដោយផាសុខភាព។ ឆ្នោតបញ្ជីរង់ចាំនឹងបិទនៅថ្ងៃទី 5 ខែវិច្ឆិកា ឆ្នាំ2018។

**តើអ្នកដែលដាក់ពាក្យស្នើសុំទាំងអស់នឹងត្រូវដាក់នៅលើបញ្ជីរង់ចាំមែនឬទេ?**

មិនដូច្នេះទេ។ យើងនឹងប្រើប្រព័ន្ធឆ្នោតផ្សងសំណាងបញ្ជីរង់ចាំ។

**តើឆ្នោតផ្សងសំណាងបញ្ជីរង់ចាំគឺជាអ្វី?**

ឆ្នោតផ្សងសំណាងបញ្ជីរង់ចាំ គឺជាប្រព័ន្ធចាប់យកដោយចៃដន្យដែលត្រូវបានប្រើប្រាស់ដោយអាជ្ញាធរលំនៅឋានជាច្រើនក្នុងការជ្រើសរើសអ្នកដាក់ពាក្យស្នើសុំសម្រាប់បញ្ជីរង់ចាំ។ វិធីសាស្ត្រនេះត្រូវបានប្រើដើម្បីបង្កើតនិងរក្សានូវទំហំនៃបញ្ជីរង់ចាំដោយសមហេតុផល។ នៅពេលដែលរយៈពេលនៃការដាក់ពាក្យស្នើសុំបញ្ជីរង់ចាំបិទ ប្រព័ន្ធសូហ្វវែរនឹងជ្រើសរើសដោយចៃចន្យនូវអ្នកដាក់ពាក្យស្នើសុំចំនួន 10,000 នាក់ដើម្បីដាក់ទៅលើបញ្ជីរង់ចាំ។

**តើខ្ញុំដាក់ពាក្យស្នើសុំឆ្នោតផ្សងសំណាងបញ្ជីរង់ចាំយ៉ាងដូចម្តេច?**

ចាប់ពីថ្ងៃទី 22 ខែតុលា ឆ្នាំ2018 វេលាម៉ោង 12:00 ព្រឹក រហូតដល់ថ្ងៃទី 5 ខែវិច្ឆិកា ឆ្នាំ2018 វេលាម៉ោង 11:59 យប់ អ្នកមានឱកាសក្នុងការដាក់ពាក្យស្នើសុំអនឡាញតាមរយៈគេហទំព័រ https://www.hacsjonline.org/។ ពាក្យស្នើសុំជាក្រដាសបោះពុម្ពមិនត្រូវបានទទួលយកឡើយ។

ដំណាក់កាលដាក់ពាក្យស្នើសុំ៖

1. ត្រូវមានអាសយដ្ឋានអ៊ីម៉ែល។ សូមផ្តល់អនុសាសន៍ថាអ្នកគួរបង្កើតគណនីអ៊ីម៉ែលមួយមុនពេលដាក់ពាក្យស្នើសុំ។ ក្រុមហ៊ុនផ្តល់សេវាអ៊ីម៉ែលដោយមិនគិតថ្លៃអាចមាននៅ yahoo.com, gmail.com, និង outlook.com.
2. អ្នកដាក់ពាក្យស្នើសុំទាំងអស់ត្រូវចុះឈ្មោះជាមួយ HACSJ នៅ Rent Café។ ដើម្បីចុះឈ្មោះ សូមចូលទៅកាន់គេហទំព័រ https://www.hacsjonline.org/។ ប្រសិនបើអ្នកបានចុះឈ្មោះជាមួយ HACSJ នៅ Rent Cafe រួចហើយ អ្នកមិនតម្រូវឱ្យចុះឈ្មោះម្តងទៀតទេ។ អ្នកអាចជ្រើសយក "អ្នកដាក់ពាក្យស្នើសុំចូលប្រើ (Applicant Login)" និងបញ្ចូលឈ្មោះអ្នកប្រើនិងពាក្យសម្ងាត់របស់អ្នក រួចជ្រើសយក "ចូលប្រើ" បន្ទាប់មកដំណើរការទៅកាន់ដំណាក់កាលទី 4 ខាងក្រោម។
3. សម្រាប់អ្នកចុះឈ្មោះថ្មី សូមចូលទៅកាន់គេហទំព័រ https://www.hacsjonline.org/:

- ជ្រើសយក "អ្នកដាក់ពាក្យស្នើសុំចូលប្រើ (Applicant Login)"
- ជ្រើសយក "ចុចទីនេះដើម្បីចុះឈ្មោះ"
- ជ្រើសយក "ខ្ញុំចង់ដាក់ពាក្យស្នើសុំ"
- ជ្រើសយក "ខ្ញុំមិនមានកូដចុះឈ្មោះទេ"
- បំពេញព័ត៌មានផ្ទាល់ខ្លួន
- បំពេញព័ត៌មានគណនី។ វាចាំបាច់ត្រូវចង់ចាំព័ត៌មានទាំងនេះ ពីព្រោះវាអាចចាំបាច់ត្រូវប្រើនៅពេលអ្នកចូលទៅកាន់គណនីរបស់អ្នកពេលក្រោយ។

4. អ្នកអាចបំពេញព័ត៌មានពាក្យស្នើសុំ។ អ្នកត្រូវមានៈ
   a. លេខសន្តិសុខសង្គមនិងកាលបរិច្ឆេទឬថ្ងៃខែឆ្នាំកំណត់សមាជិកគ្រួសារទាំងអស់ដែលបានវាយឈ្មោះនៅក្នុងពាក្យស្នើសុំបឋម។
   b. ចំណូលដុលប្រចាំឆ្នាំសរុបសម្រាប់សមាជិកគ្រួសារទាំងអស់ដែលបានវាយឈ្មោះក្នុងពាក្យស្នើសុំបឋម។
5. អ្នកនឹងទទួលបានអ៊ីម៉ែលមួយបញ្ជាក់អំពីការដាក់ពាក្យស្នើសុំបឋមរបស់អ្នក។ អ្នកក៏អាចចូលប្រើបានគ្រប់ពេលដើម្បីពិនិត្យមើលពាក្យស្នើសុំបឋមរបស់អ្នក។
6. អ៊ីម៉ែលអំពីការបញ្ជាក់មិនជានាថាពាក្យស្នើសុំបឋមរបស់អ្នកត្រូវបានជ្រើសរើសសម្រាប់ឆ្នោតផ្សងសំណាងទេ។ វាគ្រាន់តែបញ្ជាក់ថាពាក្យស្នើសុំបឋមរបស់អ្នកត្រូវបានទទួល។
7. អ្នកនឹងទទួលបានអ៊ីម៉ែលមួយក្នុងអំឡុងពេលពីរសប្តាហ៍ ក្នុងការបញ្ជាក់ថាតើពាក្យស្នើសុំបឋមរបស់អ្នកត្រូវបានជ្រើសរើសតាមរយៈឆ្នោតផ្សងសំណាងដោយចៃដន្យឬទេ។ អ្នកក៏អាចចូលទៅកាន់ទំព័រ Rent Café ដើម្បីបញ្ជាក់អំពីស្ថានភាពរបស់អ្នកផងដែរ។

**<u>តើខ្ញុំអាចដឹងថាខ្ញុំត្រូវបានជ្រើសដាក់លើបញ្ជីរង់ចាំយ៉ាងដូចម្តេច?</u>**

អ្នកដែលត្រូវបានជ្រើសរើសដោយឆ្នោតផ្សងសំណាងបញ្ជីរង់ចាំនឹងត្រូវបានជូនដំណឹងតាមរយៈអ៊ីម៉ែល។ ស្ថានភាពព័ត៌មានពាក្យស្នើសុំបឋមក៏នឹងត្រូវបានផ្តល់នៅក្នុងគណនី Rent Café របស់អ្នកផងដែរ ដែលជាវិធីដ៏មានប្រសិទ្ធភាពបំផុតក្នុងការទទួលបានព័ត៌មាននេះ។

**<u>ប្រសិនបើខ្ញុំត្រូវបានជ្រើសរើសដាក់លើបញ្ជីរង់ចាំតើខ្ញុំត្រូវធ្វើអ្វីបន្ទាប់មកទៀត?</u>**

អ្នកដាក់ពាក្យស្នើសុំទាំងអស់តម្រូវឱ្យរក្សាទុកពាក្យស្នើសុំរបស់ខ្លួន ដោយត្រូវធ្វើឱ្យប្រាកដនូវចំនួនសមាជិកក្នុងគ្រួសារ ប្រាក់ចំណូល អាសយដ្ឋាន អ៊ីម៉ែល និងលេខទូរស័ព្ទ។ អាចធ្វើដូច្នេះដោយចូលប្រើគណនី Rent Café របស់អ្នក។ អ្នកដាក់ពាក្យស្នើសុំក៏ត្រូវបានតម្រូវឱ្យឆ្លើយតបទៅនឹងសំណើរបស់អាជ្ញាធរលំនៅឋាន ក្នុងការធ្វើបច្ចុប្បន្នភាពព័ត៌មានក្នុងពាក្យស្នើសុំរបស់ពួកគេផងដែរ។ ការខកខានមិនបានឆ្លើយក្នុងកាលបរិច្ឆេទកំណត់ណាមួយនឹងនាំឱ្យមានការដកចេញពាក្យស្នើសុំ។

**<u>តើមានអ្វីកើតឡើងប្រសិនបើខ្ញុំមិនទទួលបានការជូនដំណឹងថាខ្ញុំត្រូវបានដាក់នៅលើបញ្ជីរង់ចាំ?</u>**

ប្រសិនបើអ្នកមិនត្រូវបានជូនដំណឹងថាអ្នកត្រូវបានដាក់នៅលើបញ្ជីរង់ចាំទេ អ្នកគួរតែទទួលបានអ៊ីម៉ែលប្រាប់ថាអ្នកមិនត្រូវបានជ្រើសដាក់ក្នុងឆ្នោតផ្សងសំណាងបញ្ជីរង់ចាំនោះទេ។ អ្នកក៏អាចចូលប្រើគណនី Rent Café របស់អ្នកដើម្បីពិនិត្យមើលស្ថានភាពរបស់អ្នកនៅពីរសប្តាហ៍ក្រោយបិទឆ្នោតផ្សងសំណាងបញ្ជីរង់ចាំ។

**<u>តើនរណាអាចដាក់ពាក្យស្នើសុំបាន?</u>**

គ្រប់គ្រួសារនិងបុគ្គលរាល់រូបដែលមានអាយុចាប់ពី 18 ឆ្នាំឡើងទៅ អាចដាក់ពាក្យស្នើសុំបាន។